# ថ្នាំបង្ការជំងឺ COVID-19 - សំណួរដែលបានសួរជាញឹកញាប់
## បានចាក់ថ្នាំបង្ការពេញលេញ ហើយនិង គ្រប់លក្ខណៈនិងទាន់ពេលវេលា

ដើម្បីមើលសំណួរទាំងនេះ និងសំណួរដែលបានសួរជាញឹកញាប់ផ្សេងទៀតទាក់ទងនឹងថ្នាំបង្ការ តាមអនឡាញ សូមចូលទៅកាន់ គេហទំព័រអំពីថ្នាំបង្ការជំងឺ COVID-19។

### តើការធ្វើឱ្យថ្នាំបង្ការជំងឺ COVID-19 ទាំងឡាយ "គ្រប់លក្ខណៈនិងទាន់ពេលវេលា" មានន័យយ៉ាងដូចម្ដេច?

ការធ្វើឱ្យថ្នាំបង្ការជំងឺ COVID-19 ទាំងឡាយរបស់អ្នក **គ្រប់លក្ខណៈនិងទាន់ពេលវេលា** មានន័យថា៖

- អ្នកបានទទួលចាក់ដូសនៃលំដាប់ដំបូងដែលបានណែនាំទាំងអស់ ហើយអ្នកបានទទួលចាក់ ដូសជំរុញមួយដូស នៅពេលដែលដល់ពេលកំណត់អាចទទួល -ឬក៏-
- អ្នកបានទទួលចាក់ដូសនៃលំដាប់ដំបូងដែលបានណែនាំទាំងអស់ ហើយអ្នកមិនទាន់ដល់ពេលកំណត់អាចទទួលចាក់ដូសជំរុញបាន។

នៅពេលដែលមនុស្សទាំងឡាយធ្វើឱ្យថ្នាំបង្ការជំងឺ COVID-19 របស់ពួកគេ គ្រប់លក្ខណៈនិងទាន់ពេលវេលា ពួកគេទទួលបាននូវការការពារដ៏ល្អបំផុតពីការឆ្លងជំងឺ COVID-19 កម្រិតធ្ងន់ធ្ងរ។

សូមពិនិត្យមើលផ្នែក កាលវិភាគនៃការចាក់ថ្នាំបង្ការជំងឺ COVID-19 នៅលើគេហទំព័រ VaccinateLAcounty.com សម្រាប់ព័ត៌មានអំពីដូសដំបូង និងដូសជំរុញដែលបានណែនាំឱ្យទទួលចាក់ទាំងអស់។ សម្រាប់សេចក្ដីលម្អិតបន្ថែម សូមពិនិត្យមើលចំណុច ការធ្វើឱ្យថ្នាំបង្ការជំងឺ COVID-19 របស់អ្នកគ្រប់លក្ខណៈនិងទាន់ពេលវេលា នៅលើគេហទំព័ររបស់មជ្ឈមណ្ឌលគ្រប់គ្រងនិងទប់ស្កាត់ជំងឺឆ្លង (CDC)។

### តើខ្ញុំត្រូវបានចាត់ទុកថា បានចាក់ថ្នាំបង្ការពេញលេញ នៅពេលណា?

អ្នកត្រូវបានចាត់ទុកថាបានចាក់ថ្នាំបង្ការពេញលេញ គិតចាប់តាំងពី 2 សប្ដាហ៍ បន្ទាប់ពីបានទទួលចាក់ដូសលំដាប់ដំបូងដែលបានណែនាំទាំងអស់៖

- អ្នកបានចាក់ដូសតែមួយនៃថ្នាំបង្ការជំងឺ COVID-19 ប្រភេទ Johnson & Johnson (J&J)/Janssen ឬ
- អ្នកបានចាក់ដូសទីពីរនៃថ្នាំបង្ការជំងឺ COVID-19 ប្រភេទ Pfizer (ម៉ាក COMIRNATY) ឬប្រភេទ Moderna (ម៉ាក SPIKEVAX) ឬ
- អ្នកបានទទួលចាក់ដូសថ្នាំបង្ការជំងឺ COVID-19 សកម្មដែលបានណែនាំទាំងអស់ (មិនមែនជាការព្យាបាលសាកល្បង [Placebo]) នៅក្នុងការធ្វើតេស្តសាកល្បងលក្ខណៈវេជ្ជសាស្ត្រ (clinical trial) ដោយមាន ការបញ្ជាក់ចំពោះប្រសិទ្ធិភាព។

ប្រសិនបើអ្នកបានទទួលចាក់ថ្នាំបង្ការនៅក្រៅសហរដ្ឋអាមេរិក ឬចាក់ថ្នាំបង្ការដែលលាយគ្នា សូមមើលផ្នែកខាងក្រោម។

### តើការចាក់ថ្នាំបង្ការពេញលេញ និងការដែលគ្រប់លក្ខណៈនិងទាន់ពេលវេលា មានភាពខុសគ្នាយ៉ាងដូចម្ដេច?

ស្ថានភាពខ្លះតម្រូវឱ្យបុគ្គលម្នាក់ទទួលចាក់ថ្នាំបង្ការពេញលេញ។ ឧទាហរណ៍ ការចាក់ថ្នាំបង្ការពេញលេញអាចជាតម្រូវការសម្រាប់ ការធ្វើដំណើរក្រៅប្រទេស ការចូលធ្វើការងារ ការចូលរៀន ឬការចូលទៅទីតាំងមួយចំនួន។

**ការធ្វើឱ្យថ្នាំបង្ការ គ្រប់លក្ខណៈនិងទាន់ពេលវេលា អាចមិនត្រូវបានតម្រូវចាំបាច់ទេ ក្នុងស្ថានភាពភាគច្រើននាពេលឥឡូវនេះ។ ប៉ុន្តែ វាផ្ដល់ឱ្យអ្នកនូវការការពារដ៏ល្អបំផុតប្រឆាំងនឹងជំងឺ COVID-19។**

### ប្រសិនបើខ្ញុំបានចាក់ថ្នាំបង្ការនៅក្រៅសហរដ្ឋអាមេរិក តើខ្ញុំត្រូវបានចាត់ទុកថា បានចាក់ថ្នាំបង្ការពេញលេញ ដែរឬទេ?

- **ប្រសិនបើអ្នកបានទទួលចាក់គ្រប់លំដាប់ដូសនៃថ្នាំបង្ការជំងឺ COVID-19 ដែលបានទទួលការអនុម័ត ឬបានទទួលការអនុញ្ញាតឱ្យប្រើប្រាស់ដោយរដ្ឋបាលចំណីអាហារ និងឱសថ (FDA) ឬក៏ បានចុះបញ្ជីដោយអង្គការសុខភាពពិភពលោក (WHO)៖**

  - អ្នកត្រូវបានចាត់ទុកថាបានចាក់ថ្នាំបង្ការពេញលេញ គិតចាប់តាំងពីពីរសប្តាហ៍ បន្ទាប់ពីការចាក់ដូសចុងក្រោយរបស់អ្នក។
- **ប្រសិនបើអ្នកបានទទួលចាក់ថ្នាំបង្ការជំងឺ COVID-19 ចំនួនពីរដូសផ្សេងគ្នា ដែលថ្នាំបង្ការទាំងពីរដូសនោះបានទទួលការអនុម័ត ឬបានទទួលការអនុញ្ញាតឱ្យប្រើប្រាស់ដោយរដ្ឋបាលចំណីអាហារ និងឱសថ (FDA) ឬក៏ បានចុះបញ្ជីដោយអង្គការសុខភាពពិភពលោក (WHO) ជាលំដាប់ដែលមានចំនួន 2 ដូស៖**
  - អ្នកត្រូវបានចាត់ទុកថាបានចាក់ថ្នាំបង្ការពេញលេញ គិតចាប់តាំងពីពីរសប្តាហ៍ បន្ទាប់ពីការចាក់ដូសចុងក្រោយរបស់អ្នក។ កំណត់សម្គាល់៖ មជ្ឈមណ្ឌលគ្រប់គ្រងនិងទប់ស្កាត់ជំងឺឆ្លង (CDC) មិនបានណែនាំឱ្យអ្នកលាយប្រភេទថ្នាំបង្ការជំងឺ COVID-19 សម្រាប់លំដាប់ដំបូងនោះទេ។
- **ប្រសិនបើអ្នកបានទទួលចាក់ខ្លះ ឬគ្រប់លំដាប់ទាំងអស់នៃថ្នាំបង្ការជំងឺ COVID-19 ដែលមិនបានទទួលការអនុម័ត ឬមិនបានទទួលការអនុញ្ញាតឱ្យប្រើប្រាស់ដោយរដ្ឋបាលចំណីអាហារ និងឱសថ (FDA) ឬក៏ មិនបានចុះបញ្ជីដោយអង្គការសុខភាពពិភពលោក (WHO) ទេនោះ៖**
  - អ្នកមិនត្រូវបានចាត់ទុកថា បានចាក់ថ្នាំបង្ការពេញលេញ ដោយអាជ្ញាធរនានានៅសហរដ្ឋអាមេរិកឡើយ។
  - ប្រសិនបើអ្នកចង់ទទួលបានការចាត់ទុកថា បានចាក់ថ្នាំបង្ការពេញលេញ នៅសហរដ្ឋអាមេរិក អ្នកនឹងត្រូវបញ្ចប់ការចាក់លំដាប់ថ្មីមួយនៃថ្នាំបង្ការដែលបានទទួលការអនុញ្ញាត ឬបានទទួលការអនុម័តឱ្យប្រើប្រាស់ដោយ FDA ឬក៏បានចុះបញ្ជីដោយ WHO។ អ្នកគួរតែរង់ចាំយ៉ាងហោចណាស់ 28 ថ្ងៃបន្ទាប់ពីការទទួលចាក់ដូសចុងក្រោយរបស់អ្នក មុនពេលការចាប់ផ្តើមចាក់លំដាប់ដំបូងនៃថ្នាំបង្ការជំងឺ COVID-19 ដែលបានទទួលការអនុញ្ញាត/អនុម័តឱ្យប្រើប្រាស់ដោយ FDA នោះ។
- **ប្រសិនបើអ្នកបានចាប់ផ្តើមចាក់ជាលំដាប់នូវថ្នាំបង្ការជំងឺ COVID-19 ដែលបានចុះបញ្ជីដោយអង្គការសុខភាពពិភពលោក (WHO) ប៉ុន្តែមិនមានផ្តល់ជូននៅសហរដ្ឋអាមេរិកទេ៖**
  - អ្នកមិនត្រូវបានចាត់ទុកថា បានចាក់ថ្នាំបង្ការពេញលេញ ដោយអាជ្ញាធរនានានៅសហរដ្ឋអាមេរិកឡើយ។
  - ប្រសិនបើអ្នកចូលមកដល់សហរដ្ឋអាមេរិករួចហើយ និងចង់ត្រូវបានចាត់ទុកថា បានចាក់ថ្នាំបង្ការពេញលេញ អ្នកត្រូវតែទទួលចាក់ថ្នាំបង្ការប្រភេទ mRNA (ថ្នាំបង្ការជំងឺ COVID-19 ប្រភេទ Pfizer ឬប្រភេទ Moderna) ចំនួនមួយដូស ដើម្បីត្រូវបានចាត់ទុកថា បានចាក់ថ្នាំបង្ការពេញលេញ។ អ្នកគួរតែរង់ចាំយ៉ាងហោចណាស់ 28 ថ្ងៃបន្ទាប់ពីការចាក់ដូសទីមួយនៃថ្នាំបង្ការជំងឺ COVID-19 ដែលបានចុះបញ្ជីដោយ WHO ដើម្បីបញ្ចប់ការចាក់លំដាប់ដំបូងរបស់អ្នក។ កំណត់សម្គាល់៖ កុមារដែលមានអាយុចាប់ពី 5 ទៅ 17 ឆ្នាំអាចចាក់ថ្នាំបង្ការជំងឺ COVID-19 ប្រភេទ Pfizer តែប៉ុណ្ណោះ។

សូមមើលគេហទំព័រ មនុស្សដែលបានទទួលចាក់ថ្នាំបង្ការជំងឺ COVID-19 នៅក្រៅសហរដ្ឋអាមេរិក សម្រាប់ព័ត៌មានលម្អិតបន្ថែម។

## តើខ្ញុំត្រូវបានចាត់ទុកថាបានចាក់ថ្នាំបង្ការពេញលេញដែរឬទេ ប្រសិនបើខ្ញុំបានទទួលចាក់ថ្នាំបង្ការជំងឺ COVID-19 ចំនួន 2 ផ្សេងគ្នា?

មជ្ឈមណ្ឌលគ្រប់គ្រងនិងទប់ស្កាត់ជំងឺឆ្លង (CDC) មិនណែនាំឱ្យអ្នកលាយប្រភេទថ្នាំបង្ការជំងឺ COVID-19 សម្រាប់លំដាប់ដំបូងនោះទេ។ ប៉ុន្តែប្រសិនបើអ្នកបានលាយប្រភេទគ្នា អ្នកត្រូវបានចាត់ទុកថាបានទទួលចាក់ថ្នាំបង្ការពេញលេញ គិតចាប់តាំងពី 2 សប្តាហ៍ បន្ទាប់ពីការចាក់ដូសទីពីរនៃការលាយបញ្ចូលគ្នានៃប្រភេទថ្នាំបង្ការដែលបានទទួលការអនុម័ត ឬបានទទួលការអនុញ្ញាតឱ្យប្រើប្រាស់ដោយរដ្ឋបាលចំណីអាហារ និងឱសថ (FDA) ឬបានចុះបញ្ជីដោយអង្គការសុខភាពពិភពលោក (WHO) ដែលជាលំដាប់ថ្នាំបង្ការដែលមាន 2 ដូស។ ត្រូវមានគម្លាតយ៉ាងហោចណាស់ 17 ថ្ងៃរវាងដូសទី 1 និងដូសទី 2 សម្រាប់ឱ្យអ្នកអាចត្រូវបានចាត់ទុកថា បានចាក់ថ្នាំបង្ការពេញលេញ (21 ថ្ងៃ ដោយរាប់បញ្ចូលទាំងរយៈពេលអនុគ្រោះចំនួន 4 ថ្ងៃ)។

សូមមើលគេហទំព័រ អ្នកដែលមិនមែនជាពលរដ្ឋសហរដ្ឋអាមេរិក និងអ្នកដែលមិនមែនជាជនអន្តោប្រវេសន៍សហរដ្ឋអាមេរិក៖ ធ្វើដំណើរទៅ និងមកពីសហរដ្ឋអាមេរិក របស់ CDC ដើម្បីស្វែងយល់បន្ថែម។

## តើខ្ញុំអាចទទួលបានព័ត៌មានបន្ថែមនៅទីណា?

- ដើម្បីបោះពុម្ព ឬមើលសំណួរដែលបានសួរញឹកញាប់ទាំងនេះ ឬសំណួរដែលបានសួរជាញឹកញាប់ផ្សេងទៀត ទាក់ទងនឹងប្រធានបទថ្នាំបង្ការជំងឺ COVID-19 សូមស្កេនកូដ QR នេះ ឬចូលទៅកាន់គេហទំព័រ សំណួរដែលបានសួរជាញឹកញាប់ទាក់ទងនឹងថ្នាំបង្ការជំងឺ COVID-19។
- គេហទំព័រ VaccinateLACounty.com - រួមទាំងគេហទំព័រ កាលវិភាគនៃការចាក់ថ្នាំបង្ការជំងឺ COVID-19 ដែលមានរូបភាពក្រាហ្វិចដើម្បីបង្ហាញនូវពេលណាដែលដូសនីមួយៗដល់ពេលកំណត់អាចទទួល និងព័ត៌មានស្តីពី វិធីទទួលចាក់ថ្នាំបង្ការ។
- គេហទំព័រ ថ្នាំបង្ការសម្រាប់ជំងឺ COVID-19 របស់មជ្ឈមណ្ឌលគ្រប់គ្រងនិងទប់ស្កាត់ជំងឺឆ្លង (CDC)
- ចូរពិគ្រោះជាមួយគ្រូពេទ្យរបស់អ្នក ប្រសិនបើអ្នកមានសំណួរផ្សេងៗ។